# សេចក្តីជូនដំណឹង

អង្គការសង្គមស៊ីវិល សមាគមយុវជន និងបណ្តាញយុវជន មានកិត្តិយស សូមជម្រាបជូនដំណឹង និងគោរពអញ្ជើញដល់លោក លោកស្រី នាង កញ្ញា តំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ-អន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិថា យើងនឹងមានរៀបចំវេទិការយុវជនស្តីពី «**យុវជនជនជាតិដើមភាគតិច និងឱកាសនៃការទទួលបាននូវការអប់រំ កំរិតឧត្តមសិក្សា នៅរាជធានីភ្នំពេញ**»។

វេទិការនេះត្រូវបានរៀបចំឡើង ក្រោមគម្រោងពង្រឹងសិទ្ធិអំណាចយុវជនទីប្រជុំជន ក្នុងគោលបំណងដើម្បីឲ្យពួកគេបានដឹង យល់ និងទាមទារសិទ្ធិរបស់ពួកគេដើម្បីការរស់នៅកាន់តែប្រសើរ។

**អ្នកចូលរួម** ៖ ក្រុមយុវជន ១២០នាក់

**ទីកន្លែង** ៖ **ភោជនីយដ្ឋាន ខ្មែរសូរិន**

(ផ្ទះលេខ៩ និង១១ ផ្លូវលេខ៥៧ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ)

**គោលបំណង** ៖ផ្តល់ឱកាសដល់យុវជន និងសិស្សនិស្សិតជនជាតិដើមភាគតិចបានលើកឡើងដោយផ្ទាល់ពីទុក្ខកង្វល់ បញ្ហាប្រឈម និងឱកាសនៃការទទួលបានអប់រំនៅកម្ពុជា ទៅកាន់អ្នកពាក់ព័ន្ធ ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងសិក្សាបន្ថែមពីរបៀបគ្រៀងគរឲ្យមានការគាំទ្រតាមរយៈវេបសាយ«សម្លេងយុវជន»។

**កាលបរិច្ឆេទ** ៖ **ថ្ងៃអាទិត្យ ទី០៦ ខែធ្នូ ឆ្នាំ២០១៥** (ចាប់ពីម៉ោង ៧:៣០នាទីព្រឹក ដល់ម៉ោង ១២ថ្ងៃត្រង់)

**កិច្ចសហការណ៍** ៖ អង្គការខុមហ្វ្រែល (Comfrel) សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា (CIYA) អង្គការជនជាតិដើមភាគតិចកម្ពុជា (CIPO) បណ្តាញយុវជនកម្ពុជា (CYN) បណ្តាញយុវជនខ្មែរមហានគរ (KYE) និងក្រុមយុវជនស្ម័គ្រចិត្ត។

អាស្រ័យដូចបានជម្រាបជូនខាងលើតាងនាមឲ្យក្រុមការងាររៀបចំ សូមគោរពអញ្ជើញអស់លោក លោកស្រី អ្នកនាង កញ្ញា តំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ និងអន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិ ទាំងអស់មេត្តាជ្រាប និងចូលរួមយកព័ត៌មានកុំបីខាន។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៥

**ព័ត៌មានលំអិតសូមទំនាក់ទំនង៖**

- លោក ភាព សុជា ប្រធានសមាគមស៊ីយ៉ា
  ទូរស័ព្ទលេខ៖ ០៩២ ៦១៧ ៩៩០
- លោក រិទ្ធី វីរៈ មន្ត្រីកម្មវិធីគាំទ្រការអប់រំ និងយុវជនស៊ីយ៉ា
  ទូរស័ព្ទលេខ៖ ០៩៧ ៣០៣៣ ៤៧៥
- អ្នកស្រី ភោគ ស្រីពេជ្រ មន្ត្រីគម្រោងពង្រឹងសិទ្ធិអំណាចយុវជន
  ទូរស័ព្ទលេខ៖ ០៨៩ ៨១៨ ១៧៦